ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

# អនុស្សរណៈអន្តរការិយាល័យ

ជូនចំពោះ៖ ចៅក្រម និល ណុន
ប្រធានអង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / 05 / 2019
ម៉ោង (Time/Heure): 13:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ចម្លងជូន៖ លោក/លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង
ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្ដីទី
លោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាល
មន្ត្រីច្បាប់ផ្នែកគ្រប់គ្រងតុលាការ

តាមរយៈ៖ លោក គង់ សុភី ប្រធានផ្នែកគ្រប់គ្រងតុលាការ

ពី៖ លោកស្រី **Birhane Wossen Reta** ប្រធានអង្គភាពបណ្ណសារ

កម្មវត្ថុ៖ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងស្ថានភាពវត្ថុតាងរូបវ័ន្ត ដែលលោកសាស្ត្រាចារ្យ **Walter Heynowski** បានប្រគល់ជូនអង្គជំនុំជម្រះ

១. អង្គភាពបណ្ណសារបានទទួលលិខិតរបស់លោកប្រធានអង្គជំនុំជម្រះ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១៩ ដែលលោកប្រធានបានស្នើសុំការវាយតម្លៃអំពីស្ថានភាពសម្ភារៈដែលលោកសាស្ត្រាចារ្យ Walter Heynowski បានប្រគល់ជូនអង្គជំនុំជម្រះ។ ខ្ញុំសូមធ្វើការបញ្ជាក់ថា អង្គភាពបណ្ណសាររក្សាទុកវត្ថុតាងនានាដូចខាងក្រោម នៅក្នុងបណ្ណសារដែលបានទទួលតាមរយៈក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងនៅខែធ្នូ ឆ្នាំ២០១៦៖

(១) សៀវភៅកត់ត្រាអ្នកជាប់ឃុំប្រចាំថ្ងៃដែលសរសេរដោយដៃ (ឯកសារ E3/10789 និង E3/10770)

E443/14

(២) រូបថត ឬសន្លឹករូបថតរបស់បុគ្គលដែលអាចជាអ្នកជាប់ឃុំ (ឯកសារ E3/10785, E3/10785 និង E3/10787)

(៣) រូបថតមនុស្សឈរម្នាក់ឯង (ERN 01376402) និងគម្របមួយសន្លឹកដែលមានរូបថតពីរសន្លឹកជាប់មកជាមួយ ដែលអាចជាអ្នកជាប់ឃុំ (ERN 01376405)។

ចម្លើយតបទៅនឹងសំណួររបស់លោកប្រធាន៖

**(ក) សេចក្តីពិពណ៌នាអំពីស្ថានភាពនៃការថែរក្សា ការប្រើប្រាស់ និងការចាប់កាន់វត្ថុតាងទាំងនោះ**

២. វត្ថុតាងត្រូវបានថែរក្សាទុកនៅក្នុងទូរដែកចាក់សោរ នៅក្នុងបន្ទប់បណ្ណសាររបស់ អ.វ.ត.ក ដែលមានបំពាក់ប្រព័ន្ធខ្យល់ និងម៉ាស៊ីនត្រជាក់ ២៤ ម៉ោងក្នុងមួយថ្ងៃ និង ៧ ថ្ងៃក្នុងមួយសប្តាហ៍ ក្នុងកម្រិតសីតុណ្ហភាព ១៦ អង្សារសេ។ អង្គភាពបណ្ណសារសម្រួលក្នុងការចូលពិនិត្យវត្ថុតាងនៅក្នុងបន្ទប់បណ្ណសារ តាមការអនុញ្ញាតជាធម្មតាពីអង្គជំនុំជម្រះសាលាដំបូង។ អង្គភាពបណ្ណសារក៏បានរក្សាកំណត់ត្រានៃដំណើរការគ្រប់គ្រងវត្ថុតាងផងដែរ អនុលោមតាមមាត្រា ២.៧ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក។

៣. វត្ថុតាងត្រូវបានថែរក្សាទុកនៅក្នុងប្រអប់បណ្ណសារដែលគ្មានជាតិអាស៊ីតទៅតាមបទដ្ឋានត្រឹមត្រូវ៖ ប្រអប់ចំនួនមួយសម្រាប់សៀវភៅកត់ត្រាអ្នកជាប់ឃុំ និងប្រអប់ចំនួនពីរសម្រាប់វត្ថុតាង (២) និង (៣)។ អង្គភាពបណ្ណសារបានដាក់រូបថតដាច់ពីគ្នាទាំងអស់ពីប្រភេទ (២) និងប្រភេទ (៣) នៅក្នុងសន្លឹកប្លាស្ទិកថ្លា គ្មានជាតិអាស៊ីត និងសំណុំឯកសារដើម្បីការពារសម្ភារៈទាំងនោះ និងបានបិទស្លាកនៅលើសំណុំឯកសារដោយប្រើលេខ ERN បន្តបន្ទាប់គ្នា។ រូបថតផ្សេងទៀតដែលស្អិតជាប់គ្នា និងមិនអាចផ្តាច់ចេញពីគ្នាបានដោយមិនខូចខាត ត្រូវបានដាក់នៅក្នុងថង់ដាក់វត្ថុតាងធំពីរ ដែលថង់ទាំងនោះត្រូវបានថែរក្សាទុកនៅក្នុងប្រអប់បណ្ណសារ។

៤. នៅពេលបុគ្គលិកអង្គភាពបណ្ណសារចាប់កាន់ឯកសារ ហើយភាគី ឬក្រឡាបញ្ជីពិនិត្យមើលឯកសារទាំងនោះ អង្គភាពបណ្ណសារតម្រូវឱ្យអ្នកចាប់កាន់ឯកសារនោះត្រូវពាក់ស្រោមដៃពិនិត្យភស្តុតាងធ្វើពីកប្បាស និងស្នើសុំឱ្យចាប់កាន់ឯកសារថ្នមៗ ហើយមិនត្រូវដកទំព័រដាច់ពីគ្នាចេញពីសន្លឹកប្លាស្ទិកដែលគ្មានជាតិអាស៊ីតឡើយ។

**(ខ) ថាតើ ស្ថានភាពរូបវន្តនៃសម្ភារទាំងនោះបានរងផលប៉ះពាល់ដែរឬទេ ចាប់តាំងពីពេលដែល អ.វ.ត.ក បានយកវាមកគ្រប់គ្រង**

៥. **សៀវភៅកត់ត្រាអ្នកជាប់ឃុំ៖** អង្គភាពបណ្ណសារបានវាយតម្លៃថា សៀវភៅកត់ត្រាអ្នកជាប់ឃុំស្ថិតក្នុងសភាពដើមដូចនៅពេលដែលវាមកដល់ដំបូង លើកលែងតែគ្រាប់កិប និងដែកខ្ទាស់ដែលត្រូវបានដកចេញដោយមានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង។ ទោះជាយ៉ាងណាក្តី អង្គភាពបណ្ណសារពុំអាចផ្តល់យោបល់ថាតើសារធាតុគីមី និងកម្រិតជាតិអាស៊ីតនៅលើក្រដាសទទួលរងផលប៉ះពាល់ ដោយសារការចាប់កាន់ និងការរក្សាទុកសៀវភៅកត់ត្រាអ្នកជាប់ឃុំនោះដែរឬទេ។

៦. **រូបថត/សន្លឹករូបថត៖** ដោយសារសន្លឹករូបថតដែលដាច់ពីគ្នានោះមានសភាពខូចខាតខ្លាំង អង្គភាពបណ្ណសារយល់ឃើញថា រូបថតនឹងបន្តខូចខាត និងដាច់ដោចតទៅទៀតនៅពេលចាប់កាន់នាពេលខាងមុខ។ ឧទាហរណ៍ អង្គភាពបណ្ណសារមានភាពស្ទាក់ស្ទើរក្នុងការចាប់កាន់រូបថតដែលស្អិតជាប់គ្នានោះ។ បន្ទាប់ពីទទួលបានសន្លឹករូបថតទាំងនោះរួចមក សន្លឹករូបថតជាច្រើនបានរបូតដាច់ចេញពីបណ្តុំរូបថត ហើយក៏ត្រូវដាក់ចូលទៅក្នុងសន្លឹកប្លាស្ទិកសម្រាប់ការពារ ដូចពិពណ៌នាខាងលើ។ រូបថតដែលដាច់ចេញពីគ្នា និងស្អិតជាប់គ្នា មានភាពផុយស្រួយ និង អាចដាច់រហែក។ ក្រៅពីស្ថានភាពជាក់ស្តែងរបស់សន្លឹករូបថតទាំងនោះ អង្គភាពបណ្ណសារ ពុំអាចផ្តល់យោបល់ថា តើសារធាតុគីមី ឬអាស៊ីតនៅលើក្រដាសទទួលរងផលប៉ះពាល់ដែរឬទេ ចាប់តាំងពីពេលមកដល់ អ.វ.ត.ក។

៧. **រូបថតមួយសន្លឹក និងគម្របសៀវភៅ៖** វត្ថុតាងទាំងនេះស្ថិតក្នុងស្ថានភាពដដែល ដូចពេលដែល អ.វ.ត.ក ទើបទទួលបាន គឺពុំមានភាពខូចខាតទេ។ អង្គភាពបណ្ណសារពុំអាចផ្តល់យោបល់ថាតើសារធាតុគីមី ឬអាស៊ីតនៅលើក្រដាសទទួលរងផលប៉ះពាល់ដែរឬទេ ចាប់តាំងពីបញ្ចូលទៅក្នុងបណ្ណសាររបស់ អ.វ.ត.ក។

**(គ) ថាតើ អង្គភាពបណ្ណសារមានភាពជំនាញ និងធនធាន (រួមទាំងហិរញ្ញវត្ថុ) គ្រប់គ្រាន់ដើម្បីថែរក្សាសម្ភារៈរបស់លោកសាស្ត្រាចារ្យ Heynowski សម្រាប់អំឡុងពេលនៃដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ ដែលអាចធានាបាននូវសុចរិតភាពនៃវត្ថុតាងទាំងនេះដែរឬទេ។ ប្រសិនបើពុំមានភាពជំនាញ និងធនធានគ្រប់គ្រាន់ទេ តើគួរមានវិធានការអ្វីខ្លះ ដើម្បីថែរក្សាបូរណភាពរូបវន្តនៃឯកសាររបស់សាស្ត្រាចារ្យ Heynowski?**

៨. អង្គភាពបណ្ណសារអាចបន្តថែរក្សាទុកវត្ថុតាងនៅក្នុងស្ថានភាពដដែលបាន ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ។ ភាពជំនាញរបស់អង្គភាពបណ្ណសាររួមបញ្ចូលទាំងបច្ចេកទេសក្នុងការរក្សាទុកវត្ថុតាង ដូចបានរៀបរាប់ខាងលើ។ អង្គភាពបណ្ណសារពុំមានភាពជំនាញបច្ចេកទេស ឬឯកទេស ឬសម្ភារៈបរិក្ខារសម្រាប់ការរក្សាទុក ឬអភិរក្សវត្ថុតាងទាំងនេះទេ។ ហេតុនេះ អង្គភាពបណ្ណសារមិនអាចផ្តល់យោបល់ថា តើគួរមានវិធានការណាផ្សេងទៀត ដើម្បីថែរក្សាបូរណភាពរូបវ័ន្តនៃឯកសារទាំងនេះ នៅក្នុងស្ថានភាពនេះទេ។

៩. នៅពេលបច្ចុប្បន្ននេះ ពុំមានសំណើសុំថវិកា ឬកញ្ចប់ថវិកាសម្រាប់ការបញ្ចូលក្នុងបណ្ណសារជាលក្ខណៈបច្ចេកទេស ឬជំនាញឯកទេស ឬការរក្សាទុកសម្ភាររបស់សាស្ត្រាចារ្យ Heynowski នោះទេ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងតម្រូវឲ្យមានការស្នើសុំថវិកា ដើម្បីដំណើរការកិច្ចការទាំងនេះ ឬ ការពិនិត្យទៅលើឯកសារដោយអ្នកអភិរក្សជំនាញដែលមានគុណវុឌ្ឍិពីខាងក្រៅអង្គភាពបណ្ណសារ មានសេចក្តីរីករាយក្នុងការជួយសម្រួលដល់ដំណើរការនេះ ដោយសម្របសម្រួលជាមួយការិយាល័យរដ្ឋបាល។



Original EN: 01617064-01617066